

# សេចក្ដីសង្ខេប

## ស្ដីអំពីច្បាប់អ៊ីស្លាមទាក់ទងនឹង

# ការបួស

مُختصرٌ في

# أحكام الصيام

مضحي بن عبيد الشمري

# សេចក្ដីសង្ខេបស្ដីអំពី
# ច្បាប់អ៊ីស្លាមទាក់ទងនឹង
# ការបួស

ចងក្រង និងរៀបរៀងដោយ

**មូនហ៊ី ពិន អ៊ូព៉ែន អើស្កស្ការី**

ម.ស. ១៤៤២ - គ.ស. ២០២១

# مختصر في

# أَحْكَامِ الصِّيَامِ

جمع وترتيب

مضحي بن عبيد الشمري

عضو الدعوة والإرشاد بوزارة الشؤون الإسلامية

والأوقاف والدعوة

1442هـ - 2021م

# អារម្ភកថា

“ក្នុងនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។”

សៀវភៅ«**សេចក្តីសង្ខេបស្តីអំពីច្បាប់អ៊ីស្លាមទាក់ទងនឹងការបួស**» នេះ យើងខ្ញុំបានបកប្រែចេញពីច្បាប់ដើមជាភាសាអារ៉ាប់ ដែលមានចំណងជើងថា« مختصر في أحكام الصيام » ដែលត្រូវបានចងក្រង និងរៀបរៀងដោយ លោក **មូទហ៊ី ពិន អ៊្វៃពទ អើស្វស្ហាំរី**។ វាជាអត្ថបទសង្ខេបលក្ខណៈសំណួរ-ចម្លើយ ដែលរៀបរាប់នូវបញ្ហាសំខាន់ៗទាក់ទងនឹងការបួស ដោយបានប្រមូលផ្តុំនូវប្រសាសន៍ និងការផ្តល់ជាច្បាប់ដោយព្រឹទ្ធាចារ្យទាំងពីរគឺ លោក **អាប់ទុលអាហ្សីស ពិន ពើស** និង លោក **មូហាំម៉ាត់ ពិន អ៊្វៃសេម៉ីន**។

យើងខ្ញុំរីករាយនឹងទទួលយកគំនិតយោបល់ល្អៗ ពីសំណាក់មិត្តអ្នកអានទាំងឡាយ ដើម្បីឲ្យការងារបោះពុម្ពផ្សាយសៀវភៅក្រោយៗទៀតកាន់តែល្អប្រសើរឡើង។

យើងខ្ញុំសូមបួងសួងចំពោះអល់ឡោះ សូមទ្រង់ផ្តល់នូវសុខសុវត្ថិភាពក្នុងលោក និងបរលោកដល់យើងខ្ញុំ មិត្តអ្នកអាន និងសាសនិកអ៊ីស្លាមទាំងអស់។

ភ្នំពេញ, ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១

**គណៈកម្មការបកប្រែ និងបោះពុម្ពសៀវភៅ**
**នៃសមាគមសម្របសម្រួល និងអភិវឌ្ឍន៍សង្គម**

| ល.រ | មាតិកា | ទំព័រ |
|---|---|---|
| 1 | តើអ្វីជានិយមន័យនៃការបួស.................................. ? | 7 |
| 2 | តើច្បាប់អ៊ីស្លាមចែងដូចម្តេចចំពោះការបួសនៅក្នុង.........? | 7 |
| 3 | តើអ្វីខ្លះជាលក្ខខណ្ឌនៃការបួស................................. ? | 8 |
| 4 | តើពេលណាត្រូវនៀត( តាំងចិត្ត )បួសខែរ៉ម៉ាទន............ ? | 8 |
| 5 | តើការនៀតតែមួយដងនៅយប់ដំបូងនៃខែរ៉ម៉ាទន.......... ? | 9 |
| 6 | តើអាចពឹងផ្អែកលើអាហ្សានដែលវិទ្យុខ្លះបាន............... ? | 10 |
| 7 | តើអ្វីខ្លះជាអំណះអំណាងដែលបញ្ជាក់ថាខែរ៉ម៉ាទន....... ? | 10 |
| 8 | តើច្បាប់ចែងយ៉ាងណាចំពោះអ្នកដែលបានឃើញខ្នើត... ? | 11 |
| 9 | តើគេដាក់លក្ខណ្ឌឲ្យមានសាក្សីប៉ុន្មាននាក់ដើម្បី........... ? | 11 |
| 10 | តើច្បាប់អ៊ីស្លាម អនុញ្ញាតិឲ្យប្រជាជននៃប្រទេសមួយ......? | 12 |
| 11 | តើមនុស្សប្រភេទណាខ្លះដែលច្បាប់អ៊ីស្លាមអនុញ្ញាត..... ? | 12 |
| 12 | តើមានវិធីសាស្រ្តអ្វីខ្លះក្នុងការផ្តល់ចំណីអាហារចំពោះ... ? | 15 |
| 13 | តើច្បាប់ចែងយ៉ាងណាចំពោះការទទួលទានបាយ......... ? | 15 |
| 14 | តើគេដាក់ជាសុណ្ណះ( គប្បី )ឲ្យអ្នកបួសចាប់ផ្តើមទទួល.. ? | 16 |
| 15 | តើអ្វីខ្លះជាប្រការដែលនាំឲ្យខូចបួស ?.......................... | 17 |
| 16 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះអ្នកដែលស្រាយ.... ? | 22 |
| 17 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការដុសធ្មេញនៅ.. ? | 22 |
| 18 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះបួសរបស់អ្នក........ ? | 23 |
| 19 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការប្រើថ្នាំជា......... ? | 24 |
| 20 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការឆ្លុះក្រពះ......... ? | 24 |

| | | |
|---|---|---|
| 21 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការប្រើថ្នាំ............ ? | 25 |
| 22 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការបាញ់ថ្នាំសុល... ? | 25 |
| 23 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការសុលថ្នាំគ្រាប់... ? | 25 |
| 24 | តើការនិយាយដើមគេ និងការមួលបង្កាច់គេ ធ្វើឲ្យ......... ? | 26 |
| 25 | តើគេត្រូវរំលឹកអ្នកបួសដែលទទួលទានអាហារ............. ? | 26 |
| 26 | បុគ្គលម្នាក់បានស្លាប់ខណៈគាត់ជំពាក់បួស................. ? | 27 |
| 27 | តើការបួសស៊ូណិត( ស្ម័គ្រចិត្ត )ប្រភេទណាដែលល្អ........? | 28 |
| 28 | តើអ្វីទៅជាអៀកតីកាហ្វ ?.......................................... | 29 |
| 29 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការអៀកតីកាហ្វ ?..... | 31 |
| 30 | តើពេលណាទើបគេចាប់ផ្តើមអៀកតីកាហ្វ ?.................... | 31 |
| 31 | តើពេលណាទើបអ្នកអៀកតីកាហ្វចេញអំពីការអៀក.......? | 31 |
| 32 | តើអ្វីខ្លះជាទង្វើអ្នកអៀកតីកាហ្វ ?................................ | 32 |
| 33 | តើច្បាប់ចែងយ៉ាងដូចម្តេចចំពោះការចេញរបស់អ្នក....... ? | 32 |
| 34 | តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការសឡាតតារ៉ាវីស ? | 33 |
| 35 | តើសម្រាប់ការសឡាតស៊ូណិតនៅពេលយប់ មាន........ ? | 34 |
| 36 | តើអ្វីទៅជាលក្ខណៈសំគាល់យប់ឡៃឡាតុលក៏ទើរ ?......... | 34 |
| 37 | ទូអាសំខាន់ៗមួយចំនួន................................................ | 37 |
| 38 | ទូអាពេលស្រាយបួស................................................... | 36 |
| 39 | ហ្ស៊ីកៀរក្រោយពេលសឡាតវីតៀរ................................ | 38 |
| 40 | ទូអាមួយចំនួននៅក្នុងអាល់គួរអាន................................ | 39 |
| 41 | ទូអាមួយចំនួនដែលមានក្នុងសុណ្ណៈ............................... | 42 |
| 42 | ទូអាខ្លះៗសម្រាប់គុណូតវីតៀរ.................................... | 44 |



## ① តើអ្វីជានិយមន័យនៃការបួស ?

**តាមលក្ខណៈភាសា :** ការបោះបង់ ការតម។

**តាមលក្ខណៈនៃច្បាប់អ៊ីស្លាម :** ការគោរពសក្ការៈចំពោះអល់ឡោះ ដោយការតមអាហារ ទឹក និងប្រការទាំងឡាយណាដែលនាំឲ្យខូចបួស ចាប់ពីសេតារុណ ( ហ្វាជើរ ) រះ រហូតដល់ថ្ងៃលិច។

## ② តើច្បាប់អ៊ីស្លាមចែងដូចម្តេចចំពោះការបួសនៅក្នុងខែរ៉ម៉ាទន ?

ការបួសនៅក្នុងខែរ៉ម៉ាទន**គឺជាវ៉ាជិប** ( កាតព្វកិច្ច ) មួយ ដែលអល់ឡោះបានដាក់មកលើបណ្តាខ្ញុំរបស់ទ្រង់។ ភស្តុតាងដែលបញ្ជាក់ដូច្នោះ គឺយកពីអាល់គួរអាន សុណ្ណះ និងការឯកភាពគ្នារវាងសាសនវិទូអ៊ីស្លាម។ ភស្តុតាងអំពីអាល់គួរអានគឺ បន្ទូលរបស់អល់ឡោះ :

﴿ يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ كُتِبَ عَلَيۡكُمُ ٱلصِّيَامُ كَمَا كُتِبَ عَلَى ٱلَّذِينَ مِن قَبۡلِكُمۡ لَعَلَّكُمۡ تَتَّقُونَ ١٨٣ ﴾ البقرة: 183

“ ឱបណ្តាអ្នកដែលមានជំនឿ! គេបានដាក់កាតព្វកិច្ចលើពួកអ្នកឲ្យបួស ដូចដែលគេបានដាក់លើពួកអ្នកជំនាន់មុនដែរ ដើម្បីឲ្យពួកអ្នកកោត

កោតខ្លាច។[1]”

ភស្តុតាងអំពីសុណ្ណះគឺ អាល់ពូខរី និងមូស្លីមបានរាយការណ៍នៅក្នុងគម្ពីរសហេះទាំងពីររបស់ពួកគាត់, អំពីហាទីស អាប់ទុលឡោះ ពិន អ៊ូមើរ(ﷺ) ថា រ៉ស៊ូលុលឡោះ(ﷺ) បានមានប្រសាសន៍ថា ៖

(بُني الإسلامُ علَى خَمْسٍ: شَهادةِ أنْ لا إلهَ إلاَّ اللهُ، وأنَّ مُحمَّداً عَبْدُه ورَسولُهُ، وإقامِ الصلاةِ، وإيتاءِ الزَّكاةِ، وحَجِّ البيتِ، وصَومِ رَمضانَ). رَواهُ البُخارِي ومُسلمٌ.

“គេស្ថាបនាអ៊ីស្លាមលើមូលដ្ឋានគ្រឹះប្រាំគឺ ការធ្វើសាក្សីថា«គ្មានឡើយម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវ លើកលែងតែអល់ឡោះ ហើយមូហាំម៉ាត់គឺពិតជាអ្នកនាំសាររបស់អល់ឡោះ» ការប្រតិបត្តសឡាត ការបរិច្ចាកហ្សាកាត់ ការធ្វើធម្មយាត្រា(ហាជ្ជ) និងការបួសខែរ៉ម៉ាទន។

## 3 តើអ្វីខ្លះជាលក្ខខណ្ឌនៃការបួស?

ការបួសគឺជាកាតព្វកិច្ចលើអ្នកដែលតាមលក្ខខណ្ឌខាងក្រោម៖

- មូស្លីម(អ្នកកាន់សាសនាអ៊ីស្លាម)
- គ្រប់អាយុ
- មានប្រាជ្ញាស្មារតីល្អធម្មតា
- មានលទ្ធភាពបួស។

## 4 តើពេលណាត្រូវនៀត(តាំងចិត្ត)បួសខែរ៉ម៉ាទន?

ចាំបាច់ត្រូវនៀតបួសពេលយប់ មុនពេលសេតារុណ(ហ្វាជើរ)រះ។

(1)អាល់ពើក៏រ៉ោះ : 183

ប្រសិនបើបុគ្គលម្នាក់មិនបាននៀតបួសទេ រហូតដល់សេតារុណរះនោះ ការបួសរបស់គាត់មិនត្រឹមត្រូវឡើយ។ ភស្តុតាងបញ្ជាក់យ៉ាងដូច្នោះ គឺមាននៅក្នុងសេចក្តីរាយការណ៍របស់ម៉ាលិក និងអាន់ណាសាអុី អំពីហាទីស អ៊ីបនូអូមើរ(ﷺ)ថា រ៉សូលុលឡោះ(ﷺ)បានមានប្រសាសន៍ថា :

(لاَ يَصُومُ إِلاَّ مَنْ أَجْمَعَ الصِّيَامَ قَبْلَ الْفَجْرِ) رواه مالك والنسائي.

“(បុគ្គលម្នាក់)មិនត្រូវបួសឡើយ លើកលែងតែ អ្នកដែលបាននៀតមុនពេលសេតារុណរះ”។ នេះគឺសម្រាប់បួសដែលជាកាតព្វកិច្ច(វ៉ាជិប) ដោយឡែក ការបួសសូណិត(ស្មគ្រចិត្ត)វិញ គឺអាចនៀតនៅពេលថ្ងៃបាន ដោយសំអាងលើសេចក្តីរាយការណ៍របស់មូស្លីមនៅក្នុងគម្ពីរស-ហេះរបស់គាត់ថា :

(أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ دَخَلَ عَلَى عَائِشَةَ رَضِيَ اللهُ عَنْهَا فَسَأَلَهَا هَلْ عِنْدَهَا شَيْءٌ؟ قَالَتْ: لاَ، فَقَالَ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: "إِنِّي إِذاً صَائِمٌ".)

“ជាការពិត ណាពី(ﷺ)បានចូលជួបអាអុីស្ហះ(ﷺ) ហើយបានសួរគាត់ថា «តើអូនមានអ្វីហូបទេ?» គាត់ឆ្លើយថា «គ្មានទេ»។ លោកក៏តបវិញថា «បើដូច្នោះ ខ្ញុំបួស»។

## 5 តើការនៀតតែមួយដងនៅយប់ដំបូងនៃខែរ៉ម៉ាទន គ្រប់គ្រាន់សម្រាប់ការបួសមួយខែឬទេ ឬមួយត្រូវនៀតរាល់យប់?

តាមលក្ខណៈដែលត្រឹមត្រូវគឺ ការនៀតមួយដងនៅដើមខែនោះគ្រប់គ្រាន់ហើយសម្រាប់ការបួសរយៈពេលមួយខែ។ ហេតុនេះ មិនចាំបាច់នៀតរាល់យប់នោះទេ លើកលែងតែមានមូលហេតុដែលគេអនុញ្ញាត

ឲ្យគាត់ដាច់បួស ហើយគាត់បានឈប់បួសរយៈនៅពេលថ្ងៃ ករណីនេះត្រូវនៀតបួសឡើងវិញ។

**កំណត់សម្គាល់ ៖** ប្រសិនបើអាចនៀតបួសរាល់យប់បាននោះ ជាការប្រសើរ ព្រោះអាចចេញផុតអំពីការខ្វែងយោបល់គ្នារវាងសាសនវិទូអ៊ីស្លាម។

## 6 តើអាចពឹងផ្អែកលើអាហ្សានដែលវិទ្យុខ្លះបានចេញផ្សាយដើម្បីបញ្ជាក់អំពីសេតារុណ(ហ្វាជើរ)រ៉ះ និងថ្ងៃលិចបានដែរឬទេ?

អាចពឹងផ្អែកបាន ប្រសិនបើវិទ្យុនោះត្រូវបានគេជឿជាក់។(1)

## 7 តើអ្វីខ្លះជាអំណះអំណាងដែលបញ្ជាក់ថា ខែរ៉ម៉ាទនចូលមកដល់នោះ?

អំណះអំណាងដែលបញ្ជាក់ថារ៉ម៉ាទនចូលមកដល់នោះមានពីរគឺ៖

**ទីមួយ ៖** រាប់ខែស្អាក់ហ្ពានឲ្យគ្រប់៣០ថ្ងៃ (ប្រសិនបើមិនឃើញខែនៅល្ងាចថ្ងៃទី២៩ នៃខែស្អាក់ហ្ពាន)



**ទីពីរ ៖** មើលឃើញខ្នើតខែរ៉ម៉ាទន។

---

(1)លោកព្រឹទ្ធាចារ្យ **អ៊ិបនូអូសៃមីន** ធ្លាប់បានផ្តល់ជាហ្វាតាវ៉ាដូចខាងលើ។

## 8 តើច្បាប់ចែងយ៉ាងណាចំពោះអ្នកដែលបានឃើញខ្នើតខែរ៉ម៉ាទន ឬខ្នើតខែស្ហាវវ៉ាល់តែម្នាក់ឯង ហើយគេមិនទទួលយកការធ្វើសាក្សីរបស់គាត់?

គាត់មិនត្រូវបួស ហើយក៏មិនត្រូវស្រាយដែរ លើកលែងតែជាមួយមនុស្សទូទៅ។ ដោយសំអាងលើសេចក្ដីរាយការណ៍ដែលមានក្នុងគម្ពីរដើមៀករបស់អាត់តៀរមីហ្ស៊ី និងអ្នករាយការណ៍ផ្សេងទៀតថា ពិតណាស់ រ៉សូលុលឡោះ(ﷺ) បានមានប្រសាសន៍ថា ៖

(الصَّوْمُ يَوْمَ تَصُوْمُوْنَ) رواه الترمذي صححه الألباني.

“ការបួស គឺនៅថ្ងៃដែលពួកអ្នកទាំងឡាយបួស។[1]”

ម្យ៉ាងទៀត ពាក្យថា«**ខែ**»ជាភាសាអារ៉ាប់គឺ«**អាស្ហស្ហះរ៍**» ដែលមានអត្ថន័យថា«ល្បីល្បាញ»។ ហេតុនេះ ប្រសិនបើការចូលខែ មនុស្សទាំងឡាយមិនបានដឹងនោះ បង្ហាញថា វាមិនទាន់ចូលនោះទេ។[2]

## 9 តើគេដាក់លក្ខខណ្ឌឲ្យមានសាក្សីប៉ុន្មាននាក់ដើម្បីបញ្ជាក់អំពីការចូលមកដល់នៃខែរ៉ម៉ាទន និងការចេញទៅវិញ?

គេដាក់លក្ខខណ្ឌឲ្យមានសាក្សីតែម្នាក់ប៉ុណ្ណោះ ដើម្បីបញ្ជាក់ថា ខែរ៉ម៉ាទ-នចូលមកដល់ ដោយសំអាងលើសេចក្ដីរាយការណ៍របស់អាពូដាវូទ និងអ្នកផ្សេងទៀត អំពីហាទីស អ៊ិបនូអ៊ូមើរ(رضي الله عنهما)ថា៖

(تَرَاءَى النَّاسُ الْهِلاَلَ، فَأَخْبَرْتُ رَسُوْلَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ أَنِّي رَأَيْتُهُ، فَصَامَ وَأَمَرَ النَّاسَ بِالصِّيَامِ) قال الترمذي: "والعمل عليه عند أكثر أهل العلم".

---

(1)លោកអាល់ពេីនីបានពិនិត្យនិងបញ្ជាក់ថាត្រឹមត្រូវ

(2)យោងតាមហ្វាតាវ៉ារបស់ លោកព្រឹទ្ធាចារ្យ អ៊ិបនូពេីស

“មនុស្សទាំងឡាយនាំគ្នាចាំមើលខ្នើតខែរ៉ម៉ាទន ហើយខ្ញុំបានជម្រាបរ៉សូលលុលទ្បោះថា ខ្ញុំពិតជាបានឃើញវា ខណៈនោះលោកក៏បួស និងប្រើមនុស្សទូទៅឲ្យបួសដែរ។[1]”

ដោយឡែក ការធ្វើសាក្សីដើម្បីបញ្ជាក់អំពី**ការចេញខែរ៉ម៉ាទនវិញ** គឺចាំបាច់ត្រូវមានពីរនាក់ឡើងទៅ ដោយមានការឯកភាពគ្នារវាងសាសនវិទូអ៊ីស្លាម។[2]

## 10 តើច្បាប់អ៊ីស្លាម អនុញ្ញាតិឲ្យប្រជាជននៃប្រទេសមួយ បួស និងស្រាយបួសដោយពឹងផ្អែកលើការគណនាតាមតារាសាស្ត្រ( ដូចជាប្រក្រតិទិន )ឬទេ ?

ច្បាប់អ៊ីស្លាមមិនអនុញ្ញាតនោះទេ ដោយសំអាងលើប្រសាសន៍របស់រ៉ស៊ូលុលឡោះ(ﷺ)ថា (صُوْمُوْا لِرُؤْيَتِهِ وَأَفْطِرُوْا لِرُؤْيَتِهِ) - “ចូរពួកអ្នកបួសដោយសារមើលឃើញខ្នើតខែរ៉ម៉ាទន និងស្រាយបួសវិញ ដោយសារឃើញខ្នើតខែស្ហាវ៉ាល។[3]” នៅក្នុងហាទីសនេះលោក(ﷺ)បានផ្សារភ្ជាប់ការចាប់ផ្តើម និងស្រាយបួសដោយការមើលឃើញខែ។

## 11 តើមនុស្សប្រភេទណាខ្លះដែលច្បាប់អ៊ីស្លាមអនុញ្ញាតឲ្យស្រាយបួស (អាចអត់បួសបាន )ក្នុងខែរ៉ម៉ាទន ?

(1)អ៊ីម៉ាំអាត់តៀរមីហ្ស៊ីថា ការអនុវត្តបែបនេះគឺជាទស្សនៈសាសនៈវិទូអ៊ីស្លាមភាគច្រើន។
(2)អ៊ីម៉ាំអាត់តៀរមីហ្ស៊ីថា ដើម្បីបញ្ជាក់ពីការស្រាយបួស ចាំបាច់ត្រូវមានសាក្សីជាបុរសពីរនាក់ ដោយពុំមានការខ្វែងយោបល់គ្នាឡើយរវាងសាសនវិទូអ៊ីស្លាម។
(3)រាយការណ៍ដោយ មូស្លីម

ប្រភេទមនុស្សដែលអ៊ីស្លាម អនុញ្ញាតឲ្យស្រាយបួសនៅក្នុងខែរ៉ម៉ាទន មានច្រើនប្រភេទគឺៈ

**ទីមួយ : អ្នកជម្ងឺដែលការបួសអាចបង្កគ្រោះថ្នាក់ដល់គាត់**

**ទីពីរ : អ្នកដំណើរ**

សំអាងលើបន្ទូលរបស់អល់ឡោះ :

﴿ فَمَن شَهِدَ مِنكُمُ ٱلشَّهۡرَ فَلۡيَصُمۡهُۖ وَمَن كَانَ مَرِيضًا أَوۡ عَلَىٰ سَفَرٖ فَعِدَّةٞ مِّنۡ أَيَّامٍ أُخَرَۗ ﴾ البقرة: 185

"បុគ្គលណាដែលមានវត្តមានជួបខែរ៉ម៉ាទននោះ ចូរឲ្យគេបួស ហើយបុគ្គលណាដែលមានជម្ងឺ ឬស្ថិតក្នុងការធ្វើដំណើរ (គាត់អាចស្រាយបួសបាន) ប៉ុន្តែត្រូវរាប់ចំនួនថ្ងៃដើម្បីបួសសងវិញនៅថ្ងៃក្រោយ។[1]"

**ទីបី :** ស្ត្រីដែល**មានរដូវ** និងស្ត្រីដែលធ្លាក់ឈាមក្រោយពេលសម្រាលកូន។ ភស្តុតាងដែលបញ្ជាក់អំពីបញ្ហានេះ គឺហាទីសដែលរាយការណ៍ដោយ អាល់ពូខរីនិងមូស្លីម, អំពីអាអ៊ីស្ហះ(رضي الله عنها)ថា :

(كَانَتْ إِحْدَانَا تَحِيْضُ عَلَى عَهْدِ رَسُوْلِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فَنُؤْمَرُ بِقَضَاءِ الصَّوْمِ وَلَا نُؤْمَرُ بِقَضَاءِ الصَّلَاةِ) متفق عليه.

"មានស្ត្រីម្នាក់នៃពួកយើង មករដូវនៅជំនាន់រ៉ស៊ូលុលឡោះ(ﷺ) ហើយគេបានប្រើគាត់ឲ្យបួសសងវិញ ប៉ុន្តែមិនបានប្រើឲ្យសឡាតសងវិញនោះឡើយ។"

**ទីបួន :** ស្ត្រីមាន**ផ្ទៃពោះ** និងស្ត្រី**បំបៅកូន**, សំអាងលើភស្តុតាងដែលគេរាយការណ៍អំពីណាពី(ﷺ)ថា :

---

(1)អាល់ពើក៏រ៉ោះ : ១៨៥

(إِنَّ اللّٰهَ وَضَعَ عَنِ الْمُسَافِرِ نِصْفَ الصَّلاَةِ وَالصَّوْمَ، وَعَنْ الْحُبْلَى وَالْمُرْضِعِ) رواه أحمد والترمذي وأبو داود والنسائي.

“ពិតណាស់ អល់ឡោះបានអនុគ្រោះឲ្យអ្នកដំណើរ ពាក់កណ្តាលនៃសឡាត(សឡាតបួនរ៉ក្អាត់មកត្រឹមពីររ៉ក្អាត់) និងការបួស ហើយក៏បានអនុគ្រោះឲ្យស្ត្រីដែលមានផ្ទៃពោះ និងស្ត្រីដែលបំបៅកូនផងដែរ (អនុញ្ញាតឲ្យស្រាយសិនតែត្រូវសងវិញ)។[1]”

**ទីប្រាំ ៖** មនុស្សអសមត្ថភាពក្នុងការបួស ដោយសារ**ចាស់ជរា** ឬជម្ងឺដែលគ្មានសង្ឃឹមថាអាចជាឡើងវិញ។

អាល់ពូខរី និងអ្នកផ្សេងទៀត បានរាយការណ៍អំពីហាទីស អ៊ីបនូអាប់ពើស(ﷺ) ក្នុងការបកស្រាយបន្ទូលអល់ឡោះថា៖

﴿وَعَلَى ٱلَّذِينَ يُطِيقُونَهُۥ فِدۡيَةٞ طَعَامُ مِسۡكِينٖ﴾ البقرة: 184

“ចំពោះពួកអ្នកដែលគ្មានលទ្ធភាពបួសគឺ ត្រូវផ្តល់ជាចំណីអាហារដល់អ្នកក្រីក្រ”, លោកបានបញ្ជាក់ថា ច្បាប់នេះ មិនត្រូវបានគេផ្លាស់ប្តូរឡើយ គឺសម្រាប់បុរសនិងស្ត្រីចាស់ជរាដែលគ្មានលទ្ធភាពបួស ត្រូវផ្តល់ជាចំណីអាហារដល់អ្នកក្រីក្រម្នាក់ក្នុងមួយថ្ងៃ ដែលគាត់មិនបានបួស។[2]” (ត្រូវផ្តល់ជា**អង្ករ** ឬអ្វីដែលជាអាហារសំខាន់ប្រចាំថ្ងៃរបស់មនុស្សក្នុងមួយថ្ងៃ1/4 **កន្តាំង** ប្រមាណ 0.75 **គីឡូក្រាម។** សាសនវិទូអ៊ីស្លាមខ្លះថា ក្នុងមួយថ្ងៃកន្លះកន្តាំងស្មើរនឹង 1.5 **គីឡូក្រាម** ប៉ុន្តែសាសនវិទូភាគច្រើនថា 1/4 **កន្តាំង**)។

---

(1)រាយការណ៍ដោយ អះម៉ាត់, អាត់តៀរមីហ្ស៊ី, អាពូដាវូទ និងអាន់ណាសាអ៊ី។

(2)អាល់ពើក៏រ៉ោះ ៖ ១៨៤

**កំណត់ចំណាំ** ៖ លោកព្រឹទ្ធាចារ្យ **អ៊ីបនូអ៊ូសៃមីន** បានបញ្ជាក់ថា ប្រសិនបើគេកត់ត្រាឲ្យអ្នក**ជម្ងឺ**ដែល**គ្មានសង្ឃឹម**ថានឹងអាចជានោះ ទៅជាជាសះស្បើយវិញ ក៏គេមិនទាមទារឲ្យគាត់**បួសសងវិញ**ដែរ ដោយសារកាតព្វកិច្ចរបស់គាត់បានអនុវត្តវារួច តាមរយៈការផ្ដល់ជាចំណីអាហារនោះ។

## 12 តើមានវិធីសាស្ត្រអ្វីខ្លះក្នុងការផ្ដល់ចំណីអាហារចំពោះអ្នកដែលគ្មានលទ្ធភាពបួសនោះ?



មានវិធីពីរយ៉ាងគឺ ៖

**ទីមួយ** ៖ គាត់អាចចម្អិន**អាហារ**រួច អញ្ជើញអ្នកក្រមកទទួលទាន

**ទីពីរ** ៖ អាចបែងចែកអាហារ ដល់អ្នកក្រ ទោះជាអាហារនោះចម្អិនរួច ឬមិនទាន់ចម្អិនក៏ដោយ (ដូចជាការចែក**អង្ករ**ជាដើម)។

## 13 តើច្បាប់ចែងយ៉ាងណាចំពោះការទទួលទានបាយបួសចំពោះអ្នកដែលចង់បួស?

ការទទួលទានបាយបួសគឺជាប្រការសុណ្ណះ(គប្បីធ្វើ)[1]។ ក៏ដូចគ្នាដែរ ការទទួលទានបាយបួស គឺគួរធ្វើនៅពេលមួយភាគបីចុងក្រោយនៃយប់ (ពេលទាបភ្លឺមុនពេលហ្វាជើរ៖) ដោយសំអាងលើប្រសាសន៍

(1)ដូចដែលលោកព្រឹទ្ធាចារ្យ អ៊ីបនូអ៊ូសៃមីនបានផ្ដល់ជាហ្វាតាវ៉ាបញ្ជាក់យ៉ាងដូច្នោះ។

របស់ហ្សៃទ ពិន ស្ហាពិទ(ﷺ)ថា ៖

(تَسَحَّرْنَا مَعَ رَسُوْلِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، ثُمَّ قُمْنَا إِلَى الصَّلاَةِ، قَالَ قُلْتُ: كَمْ كَانَ قَدْرُ ذَلِكَ ؟ قَالَ: قَدْرُ خَمْسِيْنَ آيَةٍ )، رواه البخاري ومسلم.

“ពួកយើងបានពិសារអាហារ ដើម្បីបួសជាមួយរ៉សូលុលឡោះ(ﷺ) បន្ទាប់មកលោកបានទៅសឡាត។ ខ្ញុំបានសួរថា តើមានរយៈពេលប៉ុន្មាន ចន្លោះពេលអាហ្សាន និងពេលពិសារអាហារដើម្បីបួសកាលនោះ? គាត់តបថា ប្រមាណជាអាចសូត្រ៥០អាយ៉ាត់។”[1] និងយោងតាមប្រសាសន៍រ៉សូលុលឡោះ(ﷺ) ថា ៖

(لاَ تَزَالُ أُمَّتِي بِخَيْرٍ مَا عَجَّلُوا الْفِطْرَ وَأَخَّرُوا السُّحُوْرَ) رواه أحمد.

“ពលរដ្ឋរបស់ខ្ញុំនៅតែស្ថិតក្នុងភាពល្អប្រសើរ ដរាបណាពួកគាត់នៅរួសរាន់ដើម្បីស្រាយបួស និងពន្យាពេលទទួលទានអាហារនៅពេលយប់ដើម្បីបួស។”[2]

គេចាត់ទុកថា បានទទួលទានអាហារដើម្បីបួសហើយ ទោះជាគេបានទទួលទានអាហារ ឬភេសជ្ជៈបន្តិចបន្តួចក៏ដោយ[3]។

## 14 តើគេដាក់ជាសុណ្ណះ(គប្បី)ឲ្យអ្នកបួសចាប់ផ្ដើមទទួលទានអាហារអ្វីមុនគេនៅពេលស្រាយ?



ការទទួលទានអាហារស្រាយបួស គួរចាប់ផ្ដើមដោយផ្លែល្មើ ប៉ុន្តែក្នុងករណីបើគ្មានវាទេ គប្បីចាប់ផ្ដើមដោយទឹក។

(1)រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម

(2)រាយការណ៍ដោយ អះម៉ាត់

(3)ដូចដែលលោកអ៊ីបនូហាជើរបានបញ្ជាក់ក្នុងសៀវភៅ “ហ្វាត់ហុលពើរី”

ភស្តុតាងគឺហាទីសអំពីសាល់ម៉ាន ពិន អាមៀរ(ﷺ)ថា រ៉ស៊ូលុលឡោះ (ﷺ) បានមានប្រសាសន៍ថា :

(إِذَا كَانَ أَحَدُكُمْ صَائِماً فَلْيُفْطِرْ عَلَى التَّمْرِ، فَإِنْ لَمْ يَجِدْ التَّمْرَ فَعَلَى الْمَاءِ، فَإِنَّ الْمَاءَ طَهُوْرٌ.) رواه الخمسة، وقال الترمذي: حديث حسن صحيح.

“នៅពេលបុគ្គលណាម្នាក់នៃពួកអ្នកបានបួស ចូរឲ្យគាត់ស្រាយវានឹងផ្លែល្មើ ប៉ុន្តែប្រសិនបើគ្មានល្មើ គាត់គួរស្រាយនឹងទឹក ព្រោះថាទឹកគឺស្អាតស្អំ។[1]”

## 15 តើអ្វីខ្លះជាប្រការដែលនាំឲ្យខូចបួស?

ប្រការដែលនាំឲ្យខូចបួសមានច្រើនដូចជា៖

**ទីមួយ : ការទទួលទានអាហារ និងពិសារទឹក**ដោយចេតនា មិនដោយសារការភ្លេចភ្លាំង។ សាសនវិទូទាំងអស់បានឯកភាពគ្នាលើបញ្ហានេះ។ អល់ឡោះបានមានបន្ទូលថា :

﴿وَكُلُوا۟ وَٱشْرَبُوا۟ حَتَّىٰ يَتَبَيَّنَ لَكُمُ ٱلْخَيْطُ ٱلْأَبْيَضُ مِنَ ٱلْخَيْطِ ٱلْأَسْوَدِ مِنَ ٱلْفَجْرِ﴾

البقرة: 187

“ចូរពួកអ្នកទទួលទានអាហារ និងពិសារទឹក(នៅពេលយប់)រហូតដល់អំបោះពណ៌សបានលេចចេញច្បាស់សម្រាប់ពួកអ្នក អំពីអំបោះពណ៌ខ្មៅនៃសេតារុណ(មានន័យថា ចូរទទួលទានអាហារនិងពិសាទឹកតាមចិត្តចុះរហូតដល់ពេលសេតារុណរះពោលគឺហ្វាជើររះមកដល់)[2]។”

---

(1)ដោយអ្នករាយការណ៍ទាំងប្រាំនាក់ ហើយលោកអាត់តៀរមីហ្ស៊ីអះអាងថា ហាទីសនេះ ល្អ ត្រឹមត្រូវ

(2)សូរ៉ោះ អាល់ពើក៏រ៉ោះ : ១៨៧



**ការជក់បារី** ក៏ស្ថិតនៅក្នុងប្រភេទនៃការទទួលទានអាហារ( ធ្វើឲ្យ**ខូចបួស** )ដែរ។[1]

ដូចគ្នាដែរ ( ខូចបួស ) ការបញ្ចូលសារធាតុអ្វីម៉្យាងចូលក្នុងច្រមុះ ដូចជាថ្នាំបាញ់បញ្ចូលរន្ធច្រមុះ។ ល។ ដូច្នេះហើយដែលសាសនវិទូអ៊ីស្លាមពីររូបគឺ លោក **អ៊ីបនូពើស** និង**អ៊ីបនូអូសៃមីុន**បានផ្តល់ជាហ្វាតាវ៉ា ដោយផ្អែកលើហាទីសឡាគីត ពិន សួពូរ៉ោះថា រ៉ស៊ូលុលឡោះ(ﷺ) បានមានប្រសាសន៍ថា :

(وَبَالِغْ فِي الاِ سْتِنْشَاقِ إِلاَّ أَنْ تَكُوْنَ صَائِماً) رواه أبو داود والترمذي والنسائي، وصححه الترمذي.

“ចូរអ្នកបឺតទឹកបញ្ចូលច្រមុះឲ្យជ្រៅ( ពេលយកវូទុ )លើកលែងតែពេលអ្នកបួស។[2]”

ដោយឡែកការប្រើ**ថ្នាំបន្តក់ចូល**ក្នុងភ្នែកវិញ **មិនធ្វើឲ្យដាច់បួស**នោះទេ។[3]

**ទីពីរ :** អ្វីៗទាំងអស់ដែលមានលក្ខណៈដូចជាការទទួលទានអាហារ និងការពិសារទឹកក្នុងការធ្វើឲ្យរាងកាយមានកម្លាំងរឹងមាំ ដូចជាការចាក់ថ្នាំជំនួសអាហារ ឬថ្នាំកម្លាំង[4]។ ល។

**ទីបី :** ការរួមដំណេកដោយការបញ្ចូលប្រដាប់ភេទបុរសក្នុងប្រដាប់ភេទស្ត្រី។ បញ្ហានេះ មានការឯកភាពគ្នាទាំងអស់រវាងសាសនវិទូអ៊ីស្លាម។ ហើយទន្ទឹមនឹងការធ្វើឲ្យដាច់បួសនោះ គេក៏ត្រូវពិន័យ ដោយការ

---
(1)លោក អ៊ីបនូអូសៃមីុន និងអ្នកផ្សេងទៀត បានផ្តល់ជាហ្វាតាវ៉ាបញ្ជាក់។

(2)រាយការណ៍ដោយ អាពូដាវូទ អាត់តៀរមីហ្ស៊ី និងអាន់ណាសាអ៊ី ហើយលោកអាត់តៀរមីហ្ស៊ីបញ្ជាក់ថាហាទីសនេះត្រឹមត្រូវ។

(3), (4)ដូចដែលលោកអ៊ីបនូពើស និងអ៊ីបនូអូសៃមីុនធ្លាប់បានបញ្ជាក់។

ដោះលែងទាសករម្នាក់ឲ្យមានសេរីភាព។ បើគេគ្មានលទ្ធភាពទេ គឺត្រូវបួសពីរខែជាប់គ្នា តែបើបុគ្គលនោះគ្មានលទ្ធភាពទៀត គឺត្រូវផ្តល់អាហារដល់អ្នកក្រីក្រចំនួន៦០នាក់។

**ទីបួន : ការជប់យកឈាម**ខ្មៅចេញពីក្បាល។ ដូចគ្នាដែរ ការ**បរិច្ចាគឈាម**ច្រើននិងការហូរឈាមច្រើន, ដោយសំអាងលើប្រសាសន៍របស់រ៉សូលុលឡោះ(ﷺ)ថា : [ ( أَفْطَرَ الْحَاجِمُ وَالْمَحْجُوْمُ ) رواه البخاري. ]
“អ្នកជប់យកឈាមខ្មៅចេញពីក្បាលឲ្យអ្នកដទៃ និងអ្នកឲ្យគេជប់ឈាមខ្មៅនោះគឺដាច់បួស”[1]។[2]

**ទីប្រាំ :** មានឈាមរដូវនិងធ្លាក់ឈាមក្រោយពេលសម្រាល។ នេះគឺនាំឲ្យខូចបួសដោយមានការឯកភាពរវាងសាសនវិទូអ៊ីស្លាម។

ពិតណាស់ អ៊ីម៉ាំអាល់ពូខរីបានរាយការណ៍អំពីហាទីស អាអ៊ីស្ហះ(رضي الله عنها)ថា ពិតប្រាកដ ណាពី(ﷺ)បានមានប្រសាសន៍ថា :

( أَلَيْسَ إِذَا حَاضَتْ لَمْ تُصَلِّ وَلَمْ تَصُمْ )

“តើស្ត្រីនៅពេលមានរដូវ គាត់មិនត្រូវបួស និងមិនសឡាតមែនទេ?”

ដោយឡែក ស្ត្រីមួយចំនួនដែលប្រើថ្នាំដើម្បីទប់រដូវក្នុងខែរ៉ម៉ាទនោះ លោកព្រឹទ្ធាចារ្យ អ៊ីបនូអូសៃមីន បានមានលើកឡើងថា “តាមយោបល់របស់ខ្ញុំនៅក្នុងបញ្ហានេះ គឺស្ត្រីមិនគប្បី**ប្រើថ្នាំ**ដើម្បីការពារមិនឲ្យមាន**ឈាមរដូវ**ក្នុងខែរ៉ម៉ាទននោះទេ”។

**ទីប្រាំមួយ :** ក្អួតដោយចេតនា ដោយសំអាងលើហាទីសដែលបានរាយ-

(1)រាយការណ៍ដោយ អាល់ពូខរី

(2)ដូច្នេះហើយ លោកព្រឹទ្ធាចារ្យ អ៊ីបនូពើស និងអ៊ីបនូអូសៃមីន ធ្លាប់បានដាក់ចេញជាហ្វាតាវ៉ា។

ការណ៍អំពីណាពី(ﷺ)ថា ៖

(مَنْ ذَرَعَهُ الْقَيْءُ فَلَيْسَ عَلَيْهِ قَضَاءٌ، وَمَنِ اسْتَقَاءَ عَمْداً فَلْيَقْضِ) رواه أبو داود والترمذي وغيرهم.

“បុគ្គលណាដែលក្អួតចេញមកដោយឯកឯងនោះ គឺមិនត្រូវបួសសងនោះទេ ហើយបុគ្គលណាដែលធ្វើឲ្យក្អួតដោយខ្លួនឯង គាត់ត្រូវបួសសងវិញ។[1]”

**ទីប្រាំពីរ ៖** ការធ្វើឲ្យចេញ**ទឹកកាម**ដោយដឹងខ្លួន ទោះជាតាមរយៈការថើប ការស្ទាបអង្អែល ឬវិធីសាស្រ្តផ្សេងៗទៀត។ ដោយសំអាងលើប្រសាសន៍របស់រ៉សូលុលឡោះ(ﷺ)នៅក្នុងហាទីសគុតស៊ីមួយថា ៖

( يَتْرُكُ طَعَامَهُ وَشَرَابَهُ وَشَهْوَتَهُ مِنْ أَجْلِي ) رواه البخاري ومسلم.

“(អ្នកបួស)គាត់បោះបង់អាហារ ទឹក និងតណ្ហារបស់គាត់ដើម្បីយើង។[2]”

**អ៊ិបនូគូហ្ទាម៉ះ**បានរំលឹកនៅក្នុងសៀវភៅ«**អាល់មូហ្គនី**»ថា ពិតណាស់ បុគ្គលណាចេញទឹកកាមដោយការថើប ឬបោសអង្អែលនោះ វានាំឲ្យខូចបួសដោយគ្មានការខ្វែងយោបល់គ្នានោះទេ តាមដែលគាត់ដឹង[3]។

**ទីប្រាំបី ៖ ការបឺតយកផ្សែង**ខ្លីមចន្ទន៍ ដោយចេតនាឲ្យវាចូលទៅក្នុងពោះ ព្រោះវាមានសារធាតុបំណែកតូចៗ។[4]

---

(1)រាយការណ៍ដោយ អាពូដាវូទ អាត់តៀរមីហ្ស៊ី និងអ្នកផ្សេងទៀត ហើយលោកព្រឹទ្ធាចារ្យ អ៊ីបនូពើស និងអ៊ីបនូអូសៃមីន ធ្លាប់បានផ្តល់ជាហ្វាតាវ៉ាផងដែរ។

(2)រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម

(3)លោកព្រឹទ្ធាចារ្យ អ៊ីបនូអូសៃមីន ធ្លាប់បានដាក់ចេញជាហ្វាតាវ៉ា

(4)លោកព្រឹទ្ធាចារ្យ អ៊ីបនូអូសៃមីន ធ្លាប់បានដាក់ចេញជាហ្វាតាវ៉ា

**ទីប្រាំបួន ៖ ការលាងឈាម**



ប្រសិនបើមានការផ្លាស់ប្តូរ ឬបន្ថែមសារធាតុបំប៉នជាលក្ខណៈអាហារ។[1]

**កំណត់សំគាល់**

- ប្រសិនបើគ្រាន់តែក្លិនផ្សេងខ្លឹមចន្ទន៍នោះ មិនខូចបួសនោះទេ
- ចំពោះគ្រឿងក្រអូបដូចជា ទឹកអប់ ឬគ្រឿងក្រអូបផ្សេងៗទៀត ដែលគ្មានបំណែកសារជាតិវានៅក្នុងនោះទេ មិនធ្វើឲ្យខូចបួសឡើយ។

ចុងបញ្ចប់នៃចំណុចនេះ លោកព្រឹទ្ធាចារ្យ**អ៊ីបនូអ៊ូសៃមីន** បានរំលឹកថា ប្រការដែលនាំឲ្យខូចបួសខាងលើ មិនធ្វើឲ្យអ្នកបួស ខូសបួសនោះទេ ទាល់តែមានលក្ខខណ្ឌបីខាងក្រោម៖

**ទីមួយ ៖** អ្នកប្រព្រឹត្តបានដឹងអំពីច្បាប់របស់វា និងដឹងអំពីពេលវេលា

**ទីពីរ ៖** អ្នកប្រព្រឹត្តដឹងថាខ្លួនគេកំពុងបួស(មិនបានភ្លេច)

**ទីបី ៖** អ្នកប្រព្រឹត្តជាអ្នកជ្រើសរើសអនុវត្តវាដោយខ្លួនឯង (គ្មានការគាបសង្កត់)។

## 16 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះអ្នកដែលស្រាយបួសដោយចេតនា ដោយគ្មានមូលហេតុស្របច្បាប់នោះ?

ការធ្វើដូច្នោះគឺស្ថិតនៅក្នុងគ្រោះថ្នាក់ធំណាស់ ព្រោះមានហាទីសអំពីអាពូអ៊ូម៉ាម៉ះ(ﷺ)ថា ខ្ញុំបានលឺរ៉ស៊ូលុលឡោះ(ﷺ)មានប្រសាសន៍ថា៖

(1)លោកព្រឹទ្ធាចារ្យអ៊ីបនូពើស និងអ៊ីបនូអ៊ូសៃមីនបានផ្តល់ហ្វាតាវ៉ា



( بَيْنَا أَنَا نَائِمٌ إِذْ أَتَانِي رَجُلاَنِ فَأَخَذَا بِضَبْعَيَّ ، وَسَاقَ الْحَدِيثَ، وَفِيهِ قَالَ: ثُمَّ انْطَلَقَا بِي فَإِذَا قَوْمٌ مُعَلَّقُونَ بِعَرَاقِيبِهِمْ، مُشَقَّقَةٌ أَشْدَاقُهُمْ تَسِيلُ أَشْدَاقُهُمْ دَمًا، قُلْتُ: مَنْ هَؤُلاَءِ؟، قَالَ: هَؤُلاَءِ الَّذِينَ يُفْطِرُونَ قَبْلَ تَحِلَّةِ صَوْمِهِمْ.) رواه النسائي في الكبرى وغيره وصححه الذهبي.

“នៅពេលខ្ញុំកំពុងសំរាន្ត ស្រាប់តែមានបុរសពីរនាក់ បានមកជួបខ្ញុំ ហើយបានកាន់ស្មាទាំងពីររបស់ខ្ញុំ។ ក្នុងនោះលោកបានបន្តថា «ក្រោយមកពួកគេទាំងពីរបាននាំខ្ញុំទៅ ស្រាប់តែខ្ញុំបានឃើញក្រុមមួយដែលត្រូវគេចងជើងព្យួរឡើងលើ ហើយត្រូវគេវាយបំបែកថ្គាមធ្វើឲ្យហូរឈាម។ ខ្ញុំបានសួរថាៈ តើពួកគេជានរណា? គេបានឆ្លើយតបថា «ពួកគេគឺជាពួកស្រាយបួសមុនពេលដល់វេលាត្រូវស្រាយ»(1)។

## 17 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការប្រើឈើមីសវ៉ាក (ឬច្រាស់ដុសធ្មេញ) នៅពេលថ្ងៃនៃខែរ៉ម៉ាទន?

---

(1)រាយការណ៍ដោយ អាន់ណាសាអុី នៅក្នុង«**ស៊ូណាន់អាល់គុបរ៉**» និងអ្នកផ្សេងទៀត ហើយហ្សាហាពីបានបញ្ជាក់ថា ហាទីសនេះត្រឹមត្រូវ។

វាជាប្រការសុណ្ណះ(គប្បីធ្វើ) ព្រោះមានហាទីស ដែលរាយការណ៍ដោយ អាល់ពូខរី អំពីអាអ៊ីស្ហះ(ﷺ)ថា ណាពី (ﷺ)បានមានប្រសាសន៍ថា ៖



( السِّوَاكُ مَطْهَرَةٌ لِلْفَمِ، مَرْضَاةٌ لِلرَّبِّ. ) رواه البخاري.

“ការដុសធ្មេញដោយប្រើឈើមីសវ៉ាក ធ្វើឲ្យមាត់ស្អាត និងធ្វើឲ្យម្ចាស់(អល់ឡោះ)ពេញចិត្ត។”

## 18 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះបួសរបស់អ្នកដែល គេអា-ហ្សានស៊ូពូហ ហើយគាត់នៅមានជូនូប( រួមដំណេករួចមិនទាន់បានងូតទឹកស្រាប់តែគេអាហ្សាន)?



ការបួសរបស់គាត់គឺត្រឹមត្រូវ គ្មានបញ្ហាឡើយ។ សាសនវិទូអ៊ីស្លាមមួយចំនួនបាននាំនូវពាក្យឯកភាពគ្នារវាងសាសនវិទូទាំងអស់លើបញ្ហានេះ។ ភស្តុតាងដែលបញ្ជាក់អំពីបញ្ហានេះគឺហាទីសនៅក្នុងសហេះអាល់ពូខរី និងមូស្លីមអំពី អាអ៊ីស្ហះ(ﷺ)ថា ៖

(أَشْهَدُ عَلَى رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ أَنَّهُ كَانَ لَيُصْبِحُ جُنُبًا مِنْ جِمَاعٍ غَيْرِ احْتِلَامٍ ثُمَّ يَصُومُ ) رواه البخاري ومسلم.

“ខ្ញុំសូមធ្វើសាក្សីចំពោះរ៉សូលុលឡោះ(ﷺ)ថា លោកធ្លាប់ពេលស៊ូពូហ

(ពេលសេតារុណរះ)មកដល់ ខណៈលោកមានជូនូបដោយការរួមដំណេកជាមួយភរិយា មិនមែនដោយការគេងយល់សប្តនោះទេ បន្ទាប់មកលោកក៏បាន(ងូតទឹកជូនូប) និងបួសធម្មតា។”

ដូចគ្នាដែរ ស្ត្រីដែលអស់រដូវឬឈប់ធ្លាក់ឈាមក្រោយសម្រាលមុនពេលសេតារុណ(ហ្វាជើរ)រះ នាងមានកាតព្វកិច្ចត្រូវបួស ទោះបីនាងមិនទាន់បានងូតទឹក លើកលែងតែក្រោយ ពេលសេតារុណ(ហ្វើជើរ)រះ ក៏ដោយ។

## 19 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការប្រើថ្នាំជាលក្ខណៈស្រ្តាយហួតសំរាប់អ្នកបួស(ដូចជាប្រេងខ្យល់ជាលក្ខណៈបំពង់ហឺតជាដើម)?

តាមលក្ខណៈដែលត្រឹមត្រូវនោះគឺ វាមិនធ្វើឲ្យខូចបួសទេ ព្រោះស្រ្តាយវាហួត មិនទៅដល់ក្នុងពោះឡើយ[1]។

## 20 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការឆ្លុះក្រពះសំរាប់អ្នកបួស?

តាមលក្ខណៈដែលត្រឹមត្រូវនោះគឺវាមិនធ្វើឲ្យខូចបួសទេ លើកលែងតែគេដាក់ជាមួយឧបករណ៍ឆ្លុះនោះ នូវសារធាតុខ្លាញ់បំប៉នកម្លាំងដើម្បីសម្រួលដល់ការបញ្ចូលវា។ ករណីនេះវាធ្វើឲ្យខូចបួសដោយសារសារធាតុនោះ មិនមែនដោយសារការបញ្ចូលឧបករណ៍ឆ្លុះនោះទេ[2]។

(1)ព្រឹទ្ធាចារ្យពីររូបគឺ លោក អ៊ីបនូពើស និង អ៊ីបនូអូសៃមីន បានផ្តល់ហ្វាតាវ៉ាបញ្ជាក់ដូច្នោះ
(2)លោកព្រឹទ្ធាចារ្យ អ៊ីបនូអូសៃមីន បានផ្តល់ហ្វាតាវ៉ាដូច្នោះ

## 21 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការប្រើថ្នាំជាលក្ខណៈក្រមួនសម្រាប់លាប( ដូចជាថ្នាំលាប ឬឡេលាបស្បែក ឬប្រេងសម្រាប់លាបស្បែក )ចំពោះអ្នកបួស ?

មិនធ្វើឲ្យខូចទេ ព្រោះវាមិនមែនជាការពិសារអាហារ ឬទឹក ហើយក៏មិនស្ថិតនៅក្នុងន័យអាហារ និងទឹកដែរ។ ដូចគ្នាដែរការបិទវត្ថុផ្សេងៗដើម្បីព្យាបាលនោះ។

## 22 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការបាញ់ថ្នាំសុលតាមរន្ធគូថចំពោះអ្នកបួស ?

តាមលក្ខណៈដែលត្រឹមត្រូវនោះគឺវាមិនធ្វើឲ្យខូចបួសទេ ព្រោះវាមិនផ្តល់កម្លាំង( ឬអាហារ )ដល់ខ្លួនប្រាណឡើយ ផ្ទុយទៅវិញ វាបញ្ចេញកាកសំណល់ផ្សេងៗដែលមាននៅក្នុងរាង្គកាយ។ លោក **អ៊ីបនូអូសៃមីន** ក៏បានផ្តល់ហ្វាតាវ៉ាបញ្ជាក់ថា ប្រសិនបើ វាជាថ្នាំធម្មតាមិនមានសារធាតុប៉ូវកម្លាំងឬសារធាតុជាអាហារនោះ គ្មានបញ្ហាឡើយ។

## 23 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការសុលថ្នាំគ្រាប់ ចំពោះអ្នកបួស ?

ការសុលថ្នាំគ្រាប់មិនធ្វើឲ្យខូចបួសនោះទេ ព្រោះវាផ្ទុកសារធាតុថ្នាំ មិនមែនដូចជាការទទួលទានអាហារ ឬពិសារទឹកឡើយ ហើយក៏មិនស្ថិត

នៅក្នុងន័យដូចគ្នាដែរ[1]។

## 24 តើការនិយាយដើមគេ និងការមួលបង្កាច់គេ ធ្វើឲ្យខូចបួសដែរឬទេ ?

មិនធ្វើឲ្យខូចបួសទេ ប៉ុន្តែវាធ្វើឲ្យខាតបង់ផលបុណ្យរបស់អ្នកបួស។ អាពូហ៊ូរ៉ៃរ៉ោះ(ﷺ)បានរាយការណ៍ថា ណាពី(ﷺ)បានមានប្រសាសន៍ថា :

( مَنْ لَمْ يَدَعْ قَوْلَ الزُّورِ وَالْعَمَلَ بِهِ فلَيْس لِلَّهِ حَاجَةٌ فِي أَنْ يَدَعَ طَعامَهُ وَشَرَابَهُ ) رواه البخاري.

“បុគ្គលណាដែលមិនព្រមបោះបង់ចោលការភូតកុហក ហើយនៅបន្តអនុវត្តវានោះ អល់ឡោះមិនត្រូវការ(ពីគេ)ឡើយ នូវការបោះបង់អាហារ និងទឹករបស់គេ(បួសរបស់គាត់)។[2]”

## 25 តើគេត្រូវរំលឹកអ្នកបួសដែលទទួលទានអាហារ ឬពិសារទឹកដោយភ្លេចខ្លួនដែរឬទេ ?

បាទ! គឺត្រូវរំលឹកគាត់។ លោកព្រឹទ្ធាចារ្យ **អ៊ីបនូអ៊ូសៃមីន** បានលើកយកភស្តុតាងបញ្ជាក់អំពីបញ្ហានេះ ដោយហាទីសដែលរាយការណ៍ដោយអាល់ពូខរី និងមូស្លីម នៅក្នុងគម្ពីរសហេះរបស់ពួកគាត់ថា ពិតណាស់ណាពី(ﷺ)បានមានប្រសាសន៍ នៅក្រោយពេលលោកបានភ្លេច

(1)ដូច្នេះទើបលោកព្រឹទ្ធាចារ្យ **អ៊ីបនូអ៊ូសៃមីន** បានផ្តល់ជាហ្វាតាវ៉ា

(2)រាយការណ៍ដោយ អាល់ពូខរី

នៅក្នុងសទ្បាតរបស់លោកថា ៖

(فَإِذَا نَسِيتُ فَذَكِّرُونِي) رواه البخاري ومسلم.

“នៅពេលដែលខ្ញុំភ្លេចនោះ ចូរពួកអ្នករំលឹកខ្ញុំមកចុះ។”

ភស្តុតាងមួយទៀតមកបញ្ជាក់ដែរគឺ ប្រសាសន៍របស់រ៉សូលុលឡោះ(ﷺ)ថា ៖

( مَنْ رَأَى مِنْكُمْ مُنْكَرًا فَلْيُغَيِّرْهُ بِيَدِهِ ، فَإِنْ لَمْ يَسْتَطِعْ فَبِلِسَانِهِ، فَإِنْ لَمْ يَسْتَطِعْ فَبِقَلْبِهِ وَذَلَكَ أَضْعَفُ الإِيمَانِ ) رواه مسلم .

“នៅពេលបុគ្គលណាម្នាក់នៃពួកអ្នក ឃើញទង្វើខុសឆ្គង ចូរអោយគាត់កែប្រែវាដោយដៃរបស់គាត់។ ប្រសិនបើគាត់គ្មានលទ្ធភាពទេ ចូរឲ្យគាត់កែប្រែវាដោយអណ្តាតរបស់គាត់។ ប្រសិនបើនៅតែគ្មានលទ្ធភាពទៀត គឺត្រូវកែប្រែគេដោយចិត្តរបស់គាត់ ហើយនេះគឺជាភាពខ្សោយបំផុតនៃជំនឿ។[1]”

## 26 បុគ្គលម្នាក់បានស្លាប់ខណៈគាត់ជំពាក់បួស តើករណីណាដែលសាច់ញាតិអាណាព្យាបាលគាត់ ត្រូវបួសជំនួសគាត់?

បញ្ហានេះ លោកព្រឹទ្ធាចារ្យ **អ៊ីបនូអ៊ូសៃមីន** បានអធិប្បាយបញ្ជាក់ដូចតទៅ៖

**ករណីទីមួយ ៖** ប្រភេទអ្នកជម្ងឺដែលឈឺហើយគ្មានសង្ឃឹមនឹងអាចជាសះស្បើយឡើងវិញ។ អ្នកជម្ងឺប្រភេទនេះ គេត្រូវផ្តល់អាហារដល់អ្នកក្រីក្រ( ក្នុងមួយថ្ងៃ1/4កន្តាំង ) មិនត្រូវបួសសងជំនួសគាត់ឡើយ។

(1)រាយការណ៍ដោយ មូស្លីម

**ករណីទីពីរ :** ប្រភេទអ្នកជម្ងឺដែលឈឺ ហើយសង្ឃឹមថានឹងអាចជាសះស្បើយឡើងវិញបាន គឺគាត់ត្រូវរាប់ថ្ងៃដែលមិនបានបួសទុក ដើម្បីបួសសងវិញ ប៉ុន្តែ ប្រសិនបើគេកត់ត្រាឲ្យគាត់ឈឺរហូតដល់គាត់ស្លាប់ (គ្មានពេលជាដើម្បីបួសសង) ករណីនេះ គឺគាត់គ្មានបាបកម្មឡើយ (មិនចាំបាច់បួសសងជំនួសគាត់ទេ) ព្រោះគាត់បានស្លាប់មុនពេលដែលគាត់មានលទ្ធភាពបួសសង។

**ករណីទីបី :** ប្រភេទអ្នកជម្ងឺដែលឈឺ ហើយសង្ឃឹមថា នឹងអាចជាសះស្បើយឡើងវិញ ហើយអល់ឡោះបានឲ្យគាត់ជាសះស្បើយពីជម្ងឺ ឬអ្នកដំណើរដែលដាច់បួស ហើយមិនបានសងដោយការធ្វេសប្រហែសរបស់គាត់ ខណៈដែលគាត់មានលទ្ធភាពបួសរហូតដល់ស្លាប់។ ករណីនេះទើបអាណាព្យាបាលគាត់ត្រូវបួសសងជំនួសគាត់។

## 27 តើការបួសស៊ូណិត(ស្ម័គ្រចិត្ត)ប្រភេទណាដែលល្អជាងគេ?

អាល់ពូខរី និងមូស្លីមបានរាយការណ៍អំពីហាទីសអាប់ទុលឡោះ ពិនអាំរ៍(ﷺ)ថា : ពិតណាស់ ណាពី(ﷺ)បានមានប្រសាសន៍ទៅកាន់គាត់ថា

(صُمْ يَوْماً وَأَفْطِرْ يوْماً ، فَذلِكَ صِيَامُ دَاوُوْدَ عَلَيْهِ السَّلاَمِ وَهُوَ أَفْضَلُ الصِّيَامِ – فَقَالَ عَبْدُ اللهِ : إِنِّيْ أُطِيقُ أَفْضَلَ مِنْ ذَلِكَ، فَقَالَ صَلّى اللهُ عَلَيْهِ وَسَلَّمَ : لاَ أَفْضَلَ مِنْ ذَلِكَ) رواه البخاري ومسلم.

“ចូរអ្នកបួសមួយថ្ងៃស្រាយមួយថ្ងៃ ដោយសារនោះគឺជាបួសរបស់ណាពីដាវូទ ( عَلَيْهِ السَّلَامُ ) ហើយវាក៏ជាបួសដែលល្អជាងគេ។ អាប់ទុលឡោះ (ﷺ)បាននិយាយប្រាប់ណាពីថា : «ខ្ញុំមានលទ្ធភាព តើមានបួសល្អជាងនេះទេ ? លោកក៏បានតបថា : គ្មានបួសណាល្អជាងនោះទេ»។”

## 28 តើអ្វីទៅជាអៀកតីកាហ្វ ?

លោកព្រឹទ្ធាចារ្យ **អ៊ីបនូអ្វូសៃមីន** បានឲ្យនិយមន័យថា អៀកតីកាហ្វ គឺជាការស្ថិតនៅក្នុងម៉ាស្ជិទ ដើម្បីធ្វើការគោរពសក្ការៈ(អ៊ីបាហ្ទាត់)ទៅចំពោះអល់ឡោះ។ វាជាប្រការសុណ្ណៈដោយឯកភាពគ្នារវាងសាសនវិទូអ៊ីស្លាម។ អល់ឡោះមានបន្ទូលថា :

﴿ أَن طَهِّرَا بَيْتِيَ لِلطَّآئِفِينَ وَٱلْعَٰكِفِينَ وَٱلرُّكَّعِ ٱلسُّجُودِ ۝١٢٥ ﴾ البقرة: 125

“យើងបានដាក់បទបញ្ជាដល់ពួកគេទាំងពីរនាក់ គឺអ៊ីព្រហ៊ីម និងអ៊ីស្មាអែល ឲ្យសម្អាតគេហដ្ឋានរបស់យើង សម្រាប់អ្នកតវ៉ាហ្វ(អ្នកដើរប្រទក្សិណជុំវិញកាក់ហ្ពះ អ្នកអៀកតិកាហ្វ អ្នករូកុ និងស៊ូជោត(អ្នកសឡាត។[1]”

មានហាទីសនៅក្នុងគម្ពីរសហេះអាល់ពូខរីនិងមូស្លីម និងគម្ពីផ្សេងទៀតថា : លោក(ﷺ)ធ្លាប់អៀកតីកាហ្វនៅដប់យប់ចុងក្រោយនៃខែរ៉ម៉ាទន។ លោកព្រឹទ្ធាចារ្យ**អ៊ីបនូពើស** បានមានប្រសាសន៍នៅក្នុងហ្វាតា-

(1)អាល់ពើក៏រ៉ោះ : ១២៥

វ៉ារបស់គាត់(១៥/៤៣៧)ថា ៖ គ្មានការមន្ទិលសង្ស័យទេថាការអៀកតីកាហ្វនៅក្នុងម៉ាស្ជិទ គឺជាទង្វើនាំឲ្យខិតជិតអល់ឡោះមួយ នៃបណ្តាទង្វើទាំងឡាយដែលនាំឲ្យខិតជិតអល់ឡោះ ហើយការធ្វើវាក្នុងខែរ៉ម៉ាទន ល្អជាងខែផ្សេងៗទៀត។ ដោយយោងតាមបន្ទូលអល់ឡោះថា ៖

﴿ وَلَا تُبَٰشِرُوهُنَّ وَأَنتُمۡ عَٰكِفُونَ فِي ٱلۡمَسَٰجِدِ﴾ البقرة: 187

“ចូរពួកអ្នកកុំប៉ះពាល់ពួកនាង(កុំប៉ះពាល់ភរិយា) ខណៈពេលពួកអ្នកកំពុងអៀកតីកាហ្វនៅក្នុងម៉ាស្ជិទ។[1]” និងយោង តាមទង្វើរបស់ណាពីដែលលោកតែងតែអៀកតីកាហ្វ នៅដប់យប់ចុងក្រោយនៃខែរ៉ម៉ាទន ហើយលោកអាក់ខានមិនបានអៀកតីកាហ្វតែមួយដងគត់ ហើយអៀកតីកាហ្វវិញនៅក្នុងខែស្ហាវ៉ាល។ **គោលបំណង**នៃការអៀកតីកាហ្វគឺយកពេលវេលា សម្រាប់តែការធ្វើការគោរពសក្ការៈ ទៅចំពោះអល់ឡោះ និងការនៅទីកន្លែងស្ងប់ស្ងាត់ជាមួយ និងការគោរពសក្ការៈទៅចំពោះអល់ឡោះ ហើយនោះគឺជាទីកន្លែងស្ងប់ស្ងាត់ដោយស្របតាមច្បាប់អ៊ីស្លាម។ មានសាសនវិទូអ៊ីស្លាមមួយចំនួនទៀតបានអោយនិយមន័យនៃការអៀកតីកាហ្វថា ៖ ជាការផ្តាច់ទំនាក់ទំនងជាមួយកិច្ចការរវល់ទាំងឡាយ ដែលរំខានការប្រតិបត្តិតាមបទបញ្ជាអល់ឡោះ និងការគោរពសក្ការៈទៅចំពោះទ្រង់។ វាជាទង្វើដែលគេប្រើទោះ ជាក្នុងខែរ៉ម៉ាទន ឬខែផ្សេងដែលបានបញ្ជាក់រួច។ ហើយប្រសិនបើរួមជាមួយការបួសនោះវាកាន់តែប្រសើរ ប៉ុន្តែប្រសិនបើបុគ្គលម្នាក់អៀកតីកាហ្វ

(1)អាល់ពើក៏រ៉ោះ ៖ ១៨៧

ដោយមិនបានបួសនោះក៏គ្មានបញ្ហាដែរ ប្រសិនបើផ្អែកតាមទស្សនៈដែលមានលក្ខណៈត្រឹមត្រូវជាងនៃទស្សនៈទាំងពីររបស់សាសនវិទូអ៊ីស្លាម។

## 29 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការអៀកតីកាហ្វ?

វាជាប្រការសុណ្ណះ ដោយមានការឯកភាពគ្នារវាងសាសនវិទូអ៊ីស្លាម។ អល់ឡោះបានបន្ទូលថា ៖

﴿ أَن طَهِّرَا بَيۡتِيَ لِلطَّآئِفِينَ وَٱلۡعَٰكِفِينَ وَٱلرُّكَّعِ ٱلسُّجُودِ ۝١٢٥ ﴾ البقرة: 125

“(យើងបានដាក់បទបញ្ជាដល់ពួកគេទាំងពីរនាក់ គឺអ៊ីព្រហ៊ីម និងអ៊ីស្មាអែល) ឲ្យសម្អាតគេហដ្ឋានរបស់យើង សម្រាប់អ្នកតវ៉ាហ្វ(អ្នកដើរប្រទក្សិនជុំវិញកាក់ពះ), អ្នកអៀកតីកាហ្វ អ្នករូកុ និងសូជូត(អ្នកសឡាត)។

## 30 តើពេលណាទើបគេចាប់ផ្ដើមអៀកតីកាហ្វ?

គេចាប់ផ្ដើមអៀកតីកាហ្វនៅយប់ទី២១នៃខែរ៉ម៉ាទន។[2]

## 31 តើពេលណាទើបអ្នកអៀកតីកាហ្វចេញអំពីការអៀកតីកាហ្វរបស់គាត់វិញ?

(1)អាល់ពើក៏រ៉ោះ ៖ ១២៥

(2)នេះជាទស្សនៈ របស់សាសនវិទូអ៊ីស្លាមភាគច្រើន ហើយលោក **អ៊ីបនូអ្វូសៃម៊ីនបានជ្រើសរើសវា។**

គាត់ត្រូវចេញអំពីការអៀកតីកាហ្វរបស់គាត់វិញ នៅពេលចប់ខែរ៉ម៉ាទន ហើយខែរ៉ម៉ាទនបញ្ចប់ដោយថ្ងៃលិចនៃយប់រ៉យ៉ា (ឃើញខ្មើតខែស្ហាវ-វ៉ាល)។

## 32 តើអ្វីខ្លះជាទង្វើអ្នកអៀកតីកាហ្វ?

គឺជាការគោរពសក្ការៈ ដែលមានលក្ខណៈពិសេសរវាងខ្ញុំបម្រើ និងអល់ឡោះ ដូចជា ការសូត្រមហាគម្ពីគួរអាន ការប្រតិបត្តិសឡាតស៊ូណិត(សឡាតដោយស្ម័គ្រចិត្តមិនមែនកាតព្វកិច្ច) ការបួងសួងសុំទូអា។ ល។

## 33 តើច្បាប់ចែងយ៉ាងដូចម្តេចចំពោះការចេញរបស់អ្នកអៀកតីកាហ្វ អំពីកន្លែងអៀកតីកាហ្វរបស់គាត់?

ការចេញរបស់អ្នកអៀកតីកាហ្វ អំពីកន្លែងអៀកតីកាហ្វរបស់គាត់គឺ ធ្វើឲ្យខូចអៀកតីកាហ្វនោះ លើកលែងតែមានការចាំបាច់ដូចជា ការយកទឹកវូហ្ទុ(ទឹកសាំប៉ះយ៉ាំង) ការបន្ទោរបង់ ការងូតទឹក។ ល។

អាល់ពូខរីនិងមូស្លីមបានរាយការណ៍នៅក្នុងគម្ពីសហេះរបស់ពួកគាត់ទាំងពីរ អំពីហាទីសអាអ៊ីស្ហះ(ﵥ)ថា ៖

(كَانَ الرَّسُول اللهِ ﷺ لاَ يَدْخُلُ الْبَيْتَ إِلاَّ لِحَاجَةٍ) رواه البخاري ومسلم.

“នៅពេលអៀកតីកាហ្វ រ៉ស៊ូលុលទ្បោះ(ﷺ) មិនចូលផ្ទះឡើយ លើកលែងតែក្នុងករណីចាំបាច់។”

អាពូដាវូទបានរាយការណ៍នៅក្នុងគម្ពីរស៊ូណាន់របស់គាត់អំពីអាអ៊ីស្ហះ(رضي الله عنها)ថា ៖

(السُّنَّةُ عَلَى الْمُعْتَكِفِ أنْ لاَ يَعُودَ مَرِيضًا، وَلاَ يَشْهَدُ جَنَازَةً، وَلاَ يَمَسَّ اِمْرَأَةً وَلاَ يُبَاشِرَهَا، وَلاَ يَخْرُجُ لِحَاجَةٍ إِلاَّ لِمَا لاَ بُدَّ مِنْهُ.) رواه أبو داود.

“តាមសុណ្ណះ សម្រាប់**អ្នកអៀកតីកាហ្វ** គឺមិនត្រូវចេញទៅសួរសុខទុក្ខអ្នកជម្ងឺ មិនត្រូវទៅចូលរួមកម្មវិធីសព(សួរសុខទុក្ខឬហែសព) រួមដំណេក ឬប៉ះពាល់ភរិយាឡើយ ហើយក៏មិនត្រូវចេញអំពីម៉ាស្ជិទនោះដែរ លើកលែងតែកិច្ចការចាំបាច់ខានមិនបាន។” អាពូដាវូទ បានបញ្ជាក់បន្ទាប់ពីសេចក្តីរាយការណ៍នេះថា ក្រៅអំពីអាប់ទុលរ៉ោះម៉ានពិន អ៊ីស្ហាក គេមិននិយាយថា អាអ៊ីស្ហះបានមានប្រសាសន៍នូវពាក្យថា «តាមសុណ្ណះ» នោះទេ។

## 34 តើច្បាប់អ៊ីស្លាមចែងយ៉ាងណាចំពោះការសទ្បាតតារ៉ាវេីស?

វាជាប្រការ**សុណ្ណះ**(គប្បីធ្វើ) ហើយរ៉ស៊ូលុលទ្បោះ(ﷺ)បានសទ្បាតវាចំនួនបីយប់(នៅម៉ាស្ជិទ)ជាមួយនឹងសហាហ្ពាត់របស់លោក។ ដោយសារតែខ្លាចគេដាក់វា(តារ៉ាវេីស)ជាវ៉ាជិប(កាតព្វកិច្ច) លោកក៏បានបោះបង់សទ្បាតនេះចោល(នៅពេលនោះ)។

## 35 តើសម្រាប់ការសឡាតស៊ូណិតនៅពេលយប់ មានកំណត់ចំនួនរ៉-ក្អាត់ដែរ ឬទេ ?

មិនមានកំណត់ចំនួនរ៉ក្អាត់ទេ ប៉ុន្តែ តាមសុណ្ណះដែលរ៉ស៊ូលុលឡោះ (ﷺ)អនុវត្តនោះគឺ **១១រ៉ក្អាត់**។

អាល់ពូខរី និងមូស្លីមបានរាយការណ៍អំពីហាទីស អាអ៊ីស្ហះ(رضي الله عنها)ថា ៖

(مَا كَانَ رَسُولُ اللَّهِ صَلّى اللهُ عَلَيْهِ وسَلَّم يَزِيدُ فِي رَمَضَانَ وَلاَ فِي غَيْرِهِ عَلَى إِحْدَى عَشْرَةَ رَكْعَةً) رواه البخاري ومسلم.

“រ៉ស៊ូលុលឡោះ(ﷺ) មិនធ្លាប់បន្ថែមសឡាតស៊ូណិតនៅពេលយប់លើសពីចំនួន**១១រ៉ក្អាត់**នោះទេ ទោះជានៅក្នុងខែរ៉ម៉ាទន ឬនៅក្នុងខែផ្សេង។”

ប៉ុន្តែ ប្រសិនបើបុគ្គលម្នាក់ប្រតិបត្តិសឡាត១៣រ៉ក្អាត់ក៏គ្មានបញ្ហាដែរ ព្រោះមានសេចក្តីរាយការណ៍ផ្សេងបានបញ្ជាក់ថា វាក៏ជាសុណ្ណះដែរ ហេតុនេះ អាចសឡាតលើសពីចំនួននេះ ឬតិចជាងនេះក៏គ្មានបញ្ហាដែរ។

## 36 តើអ្វីទៅជាលក្ខណៈសំគាល់យប់ឡៃឡាតុលក័ទឹរ ?

មានសេចក្តីរាយការណ៍ខ្លះអំពីណាពី(ﷺ) បានបញ្ជាក់អំពីលក្ខណៈរបស់វា។ ក្នុងនោះមានសេចក្តីរាយការណ៍របស់អ៊ីម៉ាំមូស្លីមនៅក្នុងគម្ពីរសហេះរបស់គាត់ អំពីហាទីសអ៊ូពៃ ពិន កាក់ព៍(رضي الله عنه)ថា ៖

(بالعَلاَمَةِ، أَوْ بالآيَةِ الَّتِي أَخْبَرَنَا رَسُوْلُ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ أَنَّهَا تَطْلُعُ يومَئِذٍ، لاَ شُعَاعَ لَهَا)

“ដោយផ្អែកលើលក្ខណៈសំគាល់ ឬភស្តុតាងដែលរ៉ស៊ូលុលឡោះ(ﷺ) បានប្រាប់ពួកយើងនោះគឺ (ព្រះអាទិត្យ)រះនៅថ្ងៃនោះ គ្មានកាំរស្មី។” ហើយវាស្ថិតនៅក្នុងដប់យប់ចុងក្រោយនៃខែរ៉ម៉ាទន ហើយគេត្រូវស្វែងរក នៅយប់សេសនៃដប់យប់នេះ។

## المراجع:

1- مفطرات الصيام المعاصرة للدكتور أحمد الخليل.

2- فتاوى الشيخ محمد بن عثيمين رحمه الله.

3- فتاوى الشيخ عبد العزيز بن باز رحمه الله.

4- شرح عمدة الفقه للشيخ د.عبد الله بن عبد العزيز بن  الجبرين.

5- وغيرها من كتب السنة.

جمع وترتيب /

مضحي بن عبيد الشمري

عضو الدعوة والإرشاد بوزارة الشؤون

الإسلامية والدعوة ةالإرشاد

# ទូអាសំខាន់ៗ មួយចំនួន

## ទូអាពេលស្រាយបួស

( ذَهَبَ الظَّمَأُ وَابْتَلَّتِ الْعُرُوقُ وَثَبَتَ الأَجْرُ إِنْ شَاءَ اللَّهُ. )

رواه أبو داود . (حسن الألباني رحمه الله)

“ការស្រេកឃ្លានត្រូវបានបាត់ទៅ ហើយសរសៃឈាមបានដើរពេញលេញវិញ និងទទួលបានផលបុណ្យ ប្រសិនបើអល់ឡោះទ្រង់សព្វព្រះរាជហទ័យ។”

## ឬសូត្រថា

( اللَّهُمَّ لَكَ صُمْتُ وَعَلَى رِزْقِكَ أَفْطَرْتُ. )

رواه أبو داود . (ضعيف)

## ហ្ស៊ីកៀរក្រោយពេលសឡាតវីតៀរ

( سُبْحَانَ الْمَلِكِ الْقُدُّوسِ )

ចំនួនបីដង

# ទូអាមួយចំនួននៅក្នុងអាល់គួរអាន

﴿رَبَّنَآ ءَاتِنَا فِي ٱلدُّنۡيَا حَسَنَةٗ وَفِي ٱلۡأٓخِرَةِ حَسَنَةٗ وَقِنَا عَذَابَ ٱلنَّارِ﴾ البقرة: 201

"ហើយក្នុងចំណោមពួកគេមានអ្នកបួងសួងថាៈ ឱម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាប្រទានដល់ពួកយើងនូវប្រការល្អ(សុខភាព ជីវភាពធូរធារ ចំណេះដឹង)នៅក្នុងលោកិយនេះ និងប្រការល្អ(ឋានសួគ៌)នាថ្ងៃបរលោក ហើយសូមរក្សាការពារពួកយើងពីទណ្ឌកម្មនៃភ្លើងនរកផង។"

﴿رَبَّنَا لَا تُؤَاخِذۡنَآ إِن نَّسِينَآ أَوۡ أَخۡطَأۡنَاۚ رَبَّنَا وَلَا تَحۡمِلۡ عَلَيۡنَآ إِصۡرٗا كَمَا حَمَلۡتَهُۥ عَلَى ٱلَّذِينَ مِن قَبۡلِنَاۚ رَبَّنَا وَلَا تُحَمِّلۡنَا مَا لَا طَاقَةَ لَنَا بِهِۦۖ وَٱعۡفُ عَنَّا وَٱغۡفِرۡ لَنَا وَٱرۡحَمۡنَآۚ أَنتَ مَوۡلَىٰنَا فَٱنصُرۡنَا عَلَى ٱلۡقَوۡمِ ٱلۡكَٰفِرِينَ﴾ البقرة: 286

"ឱម្ចាស់របស់យើង! សូមទ្រង់មេត្តាកុំចាប់កំហុសពួកយើង ប្រសិនបើពួកយើងបានភ្លេចភ្លាំង ឬជ្រុលជ្រួសដោយអចេតនា។ ឱម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាកុំដាក់ភារកិច្ចធ្ងន់ធ្ងរពេកមកលើពួកយើង ដូចដែលទ្រង់បានដាក់លើពួកអ្នកជំនាន់មុនពួកយើង។ ឱម្ចាស់របស់ពួកយើង សូមទ្រង់មេត្តាកុំដាក់បន្ទុកលើពួកយើង នូវអ្វីដែលគ្មានលទ្ធភាពសម្រាប់ពួកយើងនឹងធ្វើវា។ ហើយសូមទ្រង់មេត្តាអភ័យទោស និងអាណិតស្រលាញ់ដល់ពួកយើងផង។ ទ្រង់ជាអ្នកគាំពារពួកយើង ដូច្នេះសូមទ្រង់មេត្តាជួយពួកយើងឲ្យមានជ័យជំនះលើក្រុមដែលប្រឆាំងផង។"

﴿ رَبَّنَا لَا تُزِغْ قُلُوبَنَا بَعْدَ إِذْ هَدَيْتَنَا وَهَبْ لَنَا مِن لَّدُنكَ رَحْمَةً إِنَّكَ أَنتَ الْوَهَّابُ ﴾
آل عمران:8

“ឱម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាកុំបង្វែរចិត្តរបស់ពួកយើង ក្រោយពេលដែលទ្រង់បានចង្អុលបង្ហាញ ដល់ពួកយើងហើយនោះ។ ហើយសូមទ្រង់មេត្តាប្រទានដល់ពួកយើង នូវការអាណិតស្រឡាញ់អំពីទ្រង់ផង។ ពិតប្រាកដណាស់ ទ្រង់គឺជាអ្នកប្រទានដ៏លើសលប់។”

﴿رَبَّنَا إِنَّنَا آمَنَّا فَاغْفِرْ لَنَا ذُنُوبَنَا وَقِنَا عَذَابَ النَّارِ﴾ آل عمران: 16

“ឱម្ចាស់របស់ពួកយើង! ពួកយើងពិតជាបានជឿហើយ ដូច្នេះសូមទ្រង់មេត្តា អភ័យទោសឱ្យពួកយើងនូវបាបកម្មទាំងឡាយរបស់ពួកយើង និងការពារពួកយើងពីទណ្ឌកម្មនៃភ្លើងនរកផង។”

﴿رَبَّنَا اغْفِرْ لَنَا ذُنُوبَنَا وَإِسْرَافَنَا فِي أَمْرِنَا وَثَبِّتْ أَقْدَامَنَا وَانصُرْنَا عَلَى الْقَوْمِ الْكَافِرِينَ ﴾
آل عمران: 147

“ឱម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាអភ័យទោសដល់ពួកយើងនូវរាល់បាបកម្មរបស់យើង និងការជ្រុលជ្រួសក្នុងកិច្ចការរបស់យើងផង ហើយសូមទ្រង់មេត្តពង្រឹងគោលជំហររបស់ពួកយើង និងជួយពួកយើងឲ្យមានជ័យជំនះលើក្រុមដែលប្រឆាំងផង។”

﴿ رَبَّنَا اغْفِرْ لَنَا وَلِإِخْوَانِنَا الَّذِينَ سَبَقُونَا بِالْإِيمَانِ وَلَا تَجْعَلْ فِي قُلُوبِنَا غِلًّا لِّلَّذِينَ آمَنُوا رَبَّنَا إِنَّكَ رَءُوفٌ رَّحِيمٌ ﴾ الحشر: 10

“ឱម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាអភ័យទោសឲ្យពួកយើង និងបងប្អូនរបស់ពួកយើងពីមុនៗដែលមានជំនឿផង។ ហើយសូមទ្រង់

មេត្តាកុំឲ្យចិត្តរបស់ពួកយើងមានភាពច្រណែនឈ្នានីស ចំពោះបណ្តាអ្នកមានជំនឿ។ ឱម្ចាស់របស់យើង! ពិតប្រាកដណាស់ អល់ឡោះមហាមេត្តាករុណា មហាអាណិតស្រលាញ់។”

# ទូអាមួយចំនួនដែលមានក្នុងសុណ្ណះ

( اللَّهُمَّ اغْفِرْ لِى خَطِيئَتِى وَجَهْلِى وَإِسْرَافِى فِى أَمْرِى وَمَا أَنْتَ أَعْلَمُ بِهِ مِنِّى اللَّهُمَّ اغْفِرْ لِى جِدِّى وَهَزْلِى وَخَطَئِى وَعَمْدِى وَكُلُّ ذَلِكَ عِنْدِى اللَّهُمَّ اغْفِرْ لِى مَا قَدَّمْتُ وَمَا أَخَّرْتُ وَمَا أَسْرَرْتُ وَمَا أَعْلَنْتُ وَمَا أَنْتَ أَعْلَمُ بِهِ مِنِّى أَنْتَ الْمُقَدِّمُ وَأَنْتَ الْمُؤَخِّرُ وَأَنْتَ عَلَى كُلِّ شَىْءٍ قَدِيرٌ.) [رواه البخاري رقم (6398) ومسلم رقم (2719)]

“ឱអល់ឡោះ! សូមទ្រង់អភ័យទោសដល់ខ្ញុំនូវកំហុសឆ្គង ភាពអវិជ្ជា ការបំពានរបស់ខ្ញុំលើកិច្ចការរបស់ខ្ញុំ អចេតនានិងចេតនារបស់ខ្ញុំ និងអ្វីដែលទ្រង់ដឹងបំផុតអំពីខ្ញុំ។ ឱអល់ឡោះសូមអភ័យទោសដល់ខ្ញុំ នូវភាពពិតប្រាកដរបស់ខ្ញុំ ការលេងសើចរបស់ខ្ញុំ អចេតនានិងចេតនារបស់ខ្ញុំ ហើយទាំងអស់នេះមាននៅជាមួយខ្ញុំ។ អល់ឡោះ! សូមអភ័យទោសដល់ខ្ញុំ នូវបាបកម្មដែលខ្ញុំបានសាងកន្លងមក បាបកម្មដែលខ្ញុំមិនទាន់បានសាង បាបកម្មដែលខ្ញុំសាងដោយលាក់បាំង បាបកម្មដែលខ្ញុំសាងដោយលាតត្រដាង និងបាបកម្មដែលទ្រង់ដឹងបំផុតអំពីខ្ញុំ ទ្រង់គឺជាអ្នកដំបូងគេ ទ្រង់គឺជាអ្នកចុងក្រោយគេ ហើយទ្រង់គឺជាអ្នកមានអានុភាពលើអ្វីៗទាំងអស់។”

( اللَّهمَّ إِنِّي ظَلَمْتُ نَفْسِي ظُلْماً كثيراً ، وَلا يَغْفِر الذُّنوبَ إِلاَّ أَنْتَ ، فَاغْفِر لي مغْفِرَةً مِن عِنْدِكَ ، وارحمْني ، إِنَّك أَنْتَ الْغَفور الرَّحِيم )

[البخاري رقم (834) ورقم (6326) ومسلم رقم (2705)]

“ឱអល់ឡោះជាម្ចាស់! ខ្ញុំពិតជាបានបំពានលើខ្លួនឯងយ៉ាងខ្លាំង ហើយគ្មាននរណាម្នាក់ជាអ្នកអភ័យទោសក្រៅពីទ្រង់ឡើយ ហេតុនេះ សូមទ្រង់អភ័យទោសដល់ខ្ញុំ និងអាណិតអាសូរខ្ញុំ ពិតណាស់ទ្រង់ជាអ្នកអភ័យទោស និងអាណិតអាសូរបំផុត។”

( اللَّهُمَّ إِنِّي عَبْدُكَ ابْنُ عَبْدِكَ ابْنُ أَمَتِكَ ، نَاصِيَتِي بِيَدِكَ ، مَاضٍ فِيَّ حُكْمُكَ ، عَدْلٌ فِيَّ قَضَاؤُكَ ، أَسْأَلُكَ بِكُلِّ اسْمٍ هُوَ لَكَ ، سَمَّيْتَ بِهِ نَفْسَكَ ، أَوْ أَنْزَلْتَهُ فِي كِتَابِكَ ، أَوْ عَلَّمْتَهُ أَحَدًا مِنْ خَلْقِكَ ، أَوِ اسْتَأْثَرْتَ بِهِ فِي عِلْمِ الْغَيْبِ عِنْدَكَ ، أَنْ تَجْعَلَ الْقُرْآنَ رَبِيعَ قَلْبِي ، وَنُورَ بَصَرِي ، وَجِلَاءَ حُزْنِي ، وَذَهَابَ هَمِّي) [انظر: السلسلة الصحيحة رقم (198)]

( اللَّهُمَّ إِنِّى أَعُوذُ بِرِضَاكَ مِنْ سَخَطِكَ وَبِمُعَافَاتِكَ مِنْ عُقُوبَتِكَ وَأَعُوذُ بِكَ مِنْكَ لاَ أُحْصِى ثَنَاءً عَلَيْكَ أَنْتَ كَمَا أَثْنَيْتَ عَلَى نَفْسِكَ.) [مسلم رقم (486)]

( اللَّهُمَّ آتِ نَفْسِى تَقْوَاهَا وَزَكِّهَا أَنْتَ خَيْرُ مَنْ زَكَّاهَا أَنْتَ وَلِيُّهَا وَمَوْلاَهَا اللَّهُمَّ إِنِّى أَعُوذُ بِكَ مِنْ عِلْمٍ لاَ يَنْفَعُ وَمِنْ قَلْبٍ لاَ يَخْشَعُ وَمِنْ نَفْسٍ لاَ تَشْبَعُ وَمِنْ دَعْوَةٍ لاَ يُسْتَجَابُ لَهَا.) [مسلم رقم (2722)]

( اللَّهُمَّ إِنِّى أَسْأَلُكَ الْهُدَى وَالتُّقَى وَالْعَفَافَ وَالْغِنَى.) [مسلم رقم (2721)]

( قُولِى اللَّهُمَّ إِنَّكَ عَفُوٌّ كَرِيمٌ تُحِبُّ الْعَفْوَ فَاعْفُ عَنِّى.) [سنن الترمذي رقم (3855)]

# ទូអាខ្លះៗសម្រាប់គុណូតវីតៀរ

اللَّهُمَّ اهْدِنَا فِيمَنْ هَدَيْتَ ، وَعَافِنَا فِيمَنْ عَافَيْتَ ، وَتَوَلَّنَا فِيمَنْ تَوَلَّيْتَ ، وَبَارِكْ لَنَا فِيمَا أَعْطَيْتَ ، وَقِنَا شَرَّ مَا قَضَيْتَ ، إِنَّكَ تَقْضِي وَلَا يُقْضَى عَلَيْكَ ، وَإِنَّهُ لَا يَذِلُّ مَنْ وَالَيْتَ تَبَارَكْتَ وَتَعَالَيْتَ لَكَ الْحَمْدُ عَلَى مَا قَضَيْتَ.. وَلَكَ الشُّكْرَ عَلَى مَا أَعْطَيْتَ .. نَسْتَغْفِرُكَ اللَّهُمَّ عَلَى مِنْ جَمِيعِ الذُّنُوبِ وَالْخَطَايَا وَنَتُوبُ إِلَيكَ.

اَللَّهُمَّ اقْسِمْ لَنَا مِنْ خَشْيَتِكَ مَا يَحُولُ بَيْنَنَا وَبَيْنَ مَعَاصِيكَ، وَمِنْ طَاعَتِكَ مَا تُبَلِّغُنَا بِهِ جَنَّتَكَ، وَمِنَ الْيَقِينِ مَا تُهَوِّنُ بِهِ عَلَيْنَا مُصِيبَاتِ الدُّنْيَا، وَمَتِّعْنَا بِأَسْمَاعِنَا وَأَبْصَارِنَا وَقُوَّتِنَا مَا أَحْيَيْتَنَا ، وَاجْعَلْهُ الْوَارِثَ مِنَّا، وَاجْعَلْ ثَأْرَنَا عَلَى مَنْ ظَلَمَنَا ، وَانْصُرْنَا عَلَى مَنْ عَادَانَا وَلَا تَجْعَلْ مُصِيبَتَنَا فِي دِينِنَا، وَلَا تَجْعَلِ الدُّنْيَا أَكْبَرَ هَمِّنَا وَلَا مَبْلَغَ عِلْمِنَا، وَلَا تُسَلِّطْ عَلَيْنَا مَنْ لَا يَرْحَمُنَا. اَللَّهُمَّ أَصْلِحْ لَنَا دِينَنَا الَّذِي هُوَ عِصْمَةُ أَمْرِنَا,وَأَصْلِحْ لَنَا دُنْيَانَا الَّتِي فِيْهَا مَعَاشُنَا، وَأَصْلِحْ لَنَا آخِرَتَنَا الَّتِي فِيْهَا مَعَادُنَا، وَاجْعَلِ الْحَيَاةَ زِيَادَةً

لَنَا فِي كُلِّ خَيْر، وَاجْعَلِ الْمَوْتَ رَاحَةً لَنَا مِنْ كُلِّ شَرٍّ. اَللَّهُمَّ إِنَّنَا نَسْأَلُكَ فِعْلَ الْخَيْرَاتِ وَتَرْكِ الْمُنْكَرَاتِ وَحُبَّ الْمَسَاكِين وَأَنْ تَغْفِرَ لَنَا وَتَرْحَمْنَا وَتَتَوْبَ عَلَيْنَا.. وَإِذَا أَرَدْتَ فِتْنَةً فِي قَوْمٍ فَتَوَفَّنَا غَيْرَ مَفْتُونِينَ.. اَللَّهُمَّ إِنَّا نَسْأَلُكَ حُبَّكَ وَحُبَّ مَنْ يُحِبُّكَ وَحُبَّ عَمَلٍ يُقَرِّبُنَا إِلَى حُبِّكَ يَا رَبَّ الْعَالَمِينَ.

اَللَّهُمَّ اغْفِرْ لِلْمُسْلِمِينَ وَالْمُسْلِمَاتِ، وَالْمُؤْمِنِينَ وَالْمُؤْمِنَاتِ، وَأَصْلِحْ ذَاتَ بَيْنِهِمْ، وَأَلِّفْ بَيْنَ قُلُوبِهِمْ، وَاجْعَلْ قُلُوبَهُمْ عَلَى قُلُوبِ خِيَارِهِمْ، اَللَّهُمَّ اغْفِرْ لَنَا وَارْحَمْنَا وَأَعْتِقْ رِقَابَنَا مِنَ النَّارِ، رَبَّنَا تَقَبَّلْ مِنَّا إِنَّكَ أَنْتَ السَّمِيعُ الْعَلِيمِ، وَتُبْ عَلَيْنَا إِنَّكَ أَنْتَ التَّوَّابْ الرَّحِيمِ، وَصَلَّى اللَّهُمَّ عَلَى نَبِيِّنَا مُحَمَّدٍ وَعَلَى آلِهِ وَصَحْبِهِ وَسَلَّمْ.»

هَذَا... وَصَلَّى اللهُ عَلَى نَبِيِّنَا مُحَمَّدٍ وَعَلَى آلِهِ وَصَحْبِهِ وَسَلَّمَ تَسْلِيمًا كَثِيرًا، وَالْحَمْدُ للهِ رَبِّ الْعَالَمِينَ.

﴿ يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ كُتِبَ عَلَيۡكُمُ ٱلصِّيَامُ كَمَا كُتِبَ عَلَى ٱلَّذِينَ مِن قَبۡلِكُمۡ لَعَلَّكُمۡ تَتَّقُونَ ١٨٣ ﴾

“ឱបណ្តាអ្នកដែលមានជំនឿ! អល់ឡោះបានដាក់កាតព្វកិច្ចបួស មកលើពួកអ្នក ដូចដែលទ្រង់បានដាក់កាតព្វកិច្ចទៅលើពួកអ្នក ជំនាន់មុនៗដែរ។ សង្ឃឹមថាពួកអ្នកនឹងគោរព កោតខ្លាចអល់ឡោះ។”

គួរអាន 2: 183

ឧបត្ថម្ភការបោះពុម្ពដោយ សប្បុរសជនពីប្រទេសកូវ៉ែត
តាមរយៈ សមាគមសម្របសម្រួល និងអភិវឌ្ឍន៍សង្គម
إهداء أهل الخير من دولة الكويت
إشراف/ جمعية الرحمة العالمية
التنفيذ/ جمعية التوافق وتنمية المجتمع

EMAIL:
rdsaid.kh@gmail.com
etccenter02@gmail.com

CONTACT:
(+855) 23 23 20 12
(+855) 69 600 042

ISBN-13: 978-9924-9318-5-0